ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តកំពង់ធំ
សាលក្រម
លេខ ៤៣ "ក" ចុះថ្ងៃទី ២៧
ខែ សីហា ឆ្នាំ ២០០៤
សំណុំរឿង
លេខ ៨៤ ចុះថ្ងៃទី ១៥
ខែ មិថុនា ឆ្នាំ ២០០៤

## នាមប្រជារាស្ត្រខ្មែរ

តុលាការខេត្តកំពង់ធំ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

លោក [redacted]

**តំណាងអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៨៤ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៤ ដែលមានកម្មវត្ថុបណ្តឹង : **ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធ ។**

-រវាងដើមចោទ [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ របររកស៊ីបើកបររថយន្ត នៅភូមិកំពង់ធំ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ។

-និង ចុងចម្លើយឈ្មោះ [redacted] ភេទស្រី អាយុ ២៥ឆ្នាំ របររកស៊ីមេផ្ទះ នៅភូមិកំពង់ធំ ឃុំកំពង់ធំ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] "រ" ប្តីឈ្មោះ [redacted] មានកូន ០១នាក់ ។

## ឯរឿងហេតុមានដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ [redacted] បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធឈ្មោះ [redacted] ដោយសំអាងហេតុថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] ត្រឹមត្រូវតាមប្រពៃណីកាលពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៨ ការនៅរួមរស់ជាមួយគ្នាមិនសូវមានសុភមង្គលទេ ដោយមិនចុះសំរុងនឹងគ្នា ទើបនៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៤ ក៏ចុះបែកលំនៅសង្វាស និង មានការឯកភាពលែងលះគ្នាតែម្តង ។ ទ្រព្យសម្បត្តិដើម និង ទ្រព្យសម្បត្តិរួមគ្មានទេ ។ កូនស្រីម្នាក់ឈ្មោះ [redacted] អាយុ ០៥ឆ្នាំ ទុកអោយម្តាយគ្រប់គ្រងតាមការឯកភាពគ្នាដោយមិនទាមទារប្រាក់ អាហារកិច្ចចិញ្ចឹមកូនទេ ។

*សាលក្រមនេះចូលស្ថាពរចាប់តាំងពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ តទៅ*
*ដោយគូក្តីមិនចូលតវ៉ាតាមកំណត់ច្បាប់ ។*
*កំពង់ធំ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥*
**ប្រធានតុលាការខេត្ត**
[redacted]

-បានឃើញរបាយការណ៍ជូនរឿងទៅជំនុំជំរះលេខ ៤២៧ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៤ របស់តុលាការខេត្តកំពង់ធំ ។

-បានឃើញដីកាចាត់តាំងចៅក្រមលេខ ៤២១ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៤ របស់តុលាការខេត្តកំពង់ធំ ។

## នាពេលសវនាការ

-ដើមចោទឈ្មោះ **ត ចម** បានឆ្លើយបញ្ជាក់ថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ **គ ណាទ** ជាប្តីប្រពន្ធនឹងគ្នាកាលពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៩ ។ ទ្រព្យសម្បត្តិដើម និង ទ្រព្យសម្បត្តិរួមគ្មានទេ ។ ការនៅរួមរស់ជាមួយគ្នារហូតដល់បច្ចុប្បន្នបានកូនស្រីម្នាក់ឈ្មោះ **ត សម** អាយុ ០៥ឆ្នាំ មិនបានសេចក្តីសុខនឹងគ្នាទេ តែងមានជំលោះទាស់ទែងគ្នាជាប្រចាំធ្វើអោយខ្លួនអស់មនោសញ្ចេតនា និង រួមរស់ជាប្តីប្រពន្ធនឹងគ្នាតទៅទៀត ទើបប្តឹងសុំអោយបានដាច់សមគ្គសង្វាសពីប្រពន្ធចាប់ពីពេលនេះតទៅ ដោយសុខចិត្តយល់ព្រមប្រគល់កូនស្រីម្នាក់ឈ្មោះ **ត សម** អោយទៅចុងចម្លើយចិញ្ចឹមគ្រប់គ្រង និង យល់ព្រមផ្តល់ប្រាក់ ១.១០០ដុល្លាអោយទៅចុងចម្លើយសំរាប់ដាក់ជាប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់តទៅ ។

-អានចម្លើយចុងចម្លើយឈ្មោះ **គ ណាទ** បានឆ្លើយបញ្ជាក់ថា ខ្លួនពិតរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទត្រឹមត្រូវ តាមច្បាប់កាលពីឆ្នាំ ១៩៩៩ ប្រាកដមែន ការរួមរស់នៅជាមួយគ្នាមិនបានសេចក្តីសុខទេ ដោយឈ្លោះទាស់ទែងគ្នារាល់ថ្ងៃ ។ ខ្លួនសុំឱ្យបានដាច់សមគ្គសង្វាសពីប្តីចាប់ពីពេលនេះតទៅ ដោយសុំគ្រប់គ្រងចិញ្ចឹមកូនស្រីម្នាក់ឈ្មោះ **ត សម** អាយុ ០៥ឆ្នាំ និង សុំអោយប្តីផ្តល់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ ១.០០០ដុល្លា ។ ចំពោះទ្រព្យសម្បត្តិដើម និង ទ្រព្យសម្បត្តិរួមគ្មានទេ ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា :

ចំពោះរឿងក្តីនេះអយ្យការស្នើសុំតុលាការសំរេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់ដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ចុងចម្លើយ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តកំពង់ធំ

-យល់ឃើញថា : ពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ **ត ចម** មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-យល់ឃើញថា ដើមចោទឈ្មោះ **ត ចម** បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធឈ្មោះ **គ ណាទ** ដោយសំអាងហេតុថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ **គ ណារ** ត្រឹមត្រូវតាមប្រពៃណី កាលពីថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៩ ការនៅរួមរស់ជាមួយគ្នាមិនសូវបានសុភមង្គលទេ ដោយមិនចុះសំរុងនឹងគ្នា ទើបនៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៤ ក៏ចុះបែកលំនៅសង្វាសពីគ្នា និង ឯកភាពលែងលះគ្នាតែម្តង ។

CamScanner

-យល់ឃើញថា  ៖ មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទ និង ចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៩ មានសំបុត្រអាពាហ៍ពិពាហ៍លេខ ៦៥ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៩ ជាសំអាងច្បាស់លាស់ដល់ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៤ បានបែកលំនៅសង្វាសពីគ្នារហូតមក  ហើយស្ម័គ្រចិត្តលែងលះដោយអស់មនោសញ្ចេតនានឹងគ្នាប្រាកដមែន ។

-យល់ឃើញថា ៖ គូភាគីបានព្រមព្រៀងឯកភាពគ្នាប្រគល់កូនស្រីម្នាក់ឈ្មោះ ត សម អាយុ ០៥ឆ្នាំឱ្យទៅចុងចម្លើយចិញ្ចឹមគ្រប់គ្រង  ដោយដើមចោទយល់ព្រមប្រគល់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ១.០០០ដុល្លាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

**ហេតុដូច្នេះតុលាការខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៤ របស់ដើមចោទឈ្មោះ ត  ចម  ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យដើមចោទឈ្មោះ ត  ចម  និង ចុងចម្លើយឈ្មោះ គ  ណាទ  ដាច់សមគ្គសង្វាសពីគ្នា តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ចាប់ពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។ ដាក់កំហុសលើដើមចោទ ។

៣-ឱ្យឈ្មោះនាង គ ណាទ ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤-ប្រគល់កូនស្រីម្នាក់ឈ្មោះ ត  សម  អាយុ ០៥ឆ្នាំឱ្យទៅចុងចម្លើយឈ្មោះ គ  ណាទ គ្រប់គ្រងចិញ្ចឹមថែរក្សាតាមការព្រមព្រៀងឯកភាពរបស់គូភាគី  ។ ទុកសិទ្ធិឱ្យដើមចោទទៅសួរសុខទុក្ខកូនបានតាមមាត្រា ៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-អោយដើមចោទឈ្មោះ ត ចម ផ្តល់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ១.០០០ដុល្លាអាមេរិកទៅចុងចម្លើយឈ្មោះ គ ណាទ តាមការព្រមព្រៀងឯកភាពរបស់គូភាគី  ។ ប្រាក់នេះចុងចម្លើយឈ្មោះ គ  ណាទ  បានទទួលរួចហើយ ។

៦-សំរេចរឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛០០ ដែលដើមចោទបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី ពន្ធហ្នឹង ១.៨០០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛០០ រង្វាន់ប្រគល់ដីកាកោះ ៥.០០០៛០០ ។

៧-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទឈ្មោះ ត ចម កំបាំងមុខចុងចម្លើយឈ្មោះ គ  ណាទ ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា  និង  ត្រា**

[redacted]

**បានឃើញ**

**ប្រធានតុលាការខេត្ត**

[redacted]

CamScanner